រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# ការអនុវត្តន៍ល្អ

## សំភារៈការពារខ្លួននៅផ្នែកជ្រលក់ពណ៌

ដោយសារតែសារធាតុគីមីជ្រលក់ពណ៌ជាច្រើន បង្ករអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព និងសុវត្ថិភាព ដូចនេះរោងចក្រត្រូវផ្តល់សំភារៈការពារខ្លួន (PPE) ដល់កម្មករនៅក្នុងផ្នែកជ្រលក់ពណ៌ ។ ឧទាហរណ៍សារធាតុគីមីដែលប្រើនៅក្នុងផ្នែកជ្រលក់ពណ៌ អាចបង្ករអោយរលាកស្បែក ហើយអាចមានគ្រោះថ្នាក់ប្រសិនបើត្រូវបានស្រូបចូលតាមផ្លូវដង្ហើម ។

### ការអនុវត្តន៍ល្អសំរាប់សំភារៈការពារខ្លួននៅផ្នែកជ្រលក់ពណ៌

ត្រូវប្រគល់អោយកម្មករនូវសំភារៈដែលចាំបាច់ ដើម្បីអោយពួកគេបំពេញការងារប្រកបដោយសុវត្ថិភាព ។

ផ្តល់សំភារៈការពារខ្លួនអោយទៅកម្មករ ដើម្បីការពារពួកគេមិនអោយទទួលរងនឹងសារធាតុគ្រោះថ្នាក់ ។ សំភារៈទាំងនេះរួមមាន ម៉ាស់សុវត្ថិភាព ស្បែកជើងកវែង ស្រោមដៃ អាវអៀម និងវ៉ែនតាការពារ (រូបភាពទី១)

អប់រំកម្មករពីៈ

- គ្រោះថ្នាក់ដែលអាចកើតមានចំពោះគេ ប្រសិនបើគេមិនពាក់សំភារៈការពារខ្លួនបានត្រឹមត្រូវ ។
- របៀបពាក់សំភារៈការពារខ្លួនដែលត្រឹមត្រូវ ដើម្បីអោយមានការការពារខ្ពស់ និង
- របៀបប្រើប្រាស់ និងទុកដាក់សារធាតុគីមីប្រកបដោយសុវត្ថិភាព ។

បិទសន្លឹកទិន្នន័យពត៌មានស្តីពីសុវត្ថិភាពគីមី (MSDSs) តាមជញ្ជាំងនៅផ្នែកជ្រលក់ពណ៌ ដើម្បីអោយកម្មករអាចទទួលបានពត៌មានពីសារធាតុគីមី ដែលពួកគេកំពុងប្រើប្រាស់ ។

បិទក្រដាសពត៌មាន និងសញ្ញាតាមជញ្ជាំង ដើម្បីផ្តល់អោយកម្មករនូវពត៌មានបន្ថែមអំពីផលិតផលគីមី និងប្រាប់កម្មករពីពេលណា និងរបៀបណាក្នុងការប្រើប្រាស់សំភារៈការពារខ្លួន ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្ហាញពីទស្សនៈល្អនៅកន្លែងធ្វើការងារ
- ✓ លើកកំពស់សុវត្ថិភាព និងសុខភាពរបស់កម្មករ
- ✓ ផ្តល់សុវត្ថិភាពបន្ថែមដល់កម្មករ

### តាមរបៀបណា:

- ✓ ទិញសំភារៈការពារខ្លួនត្រឹមត្រូវសំរាប់ការប្រើប្រាស់នៅក្នុងផ្នែកជ្រលក់ពណ៌
- ✓ បកប្រែសន្លឹកទិន្នន័យពត៌មានស្តីពីសុវត្ថិភាពគីមី (MSDSs) ទៅជាភាសាខ្មែរ និងចិន សំរាប់អោយកម្មករអាន
- ✓ អនុវត្តកម្មវិធីបណ្តុះបណ្តាលជាប្រចាំស្តីពីសុវត្ថិភាពដល់កម្មករទាំងអស់
- ✓ ប្រើប្រាស់ផ្ទាំងក្រដាសពត៌មាន ស្តីពីបញ្ហាសុវត្ថិភាព ។ បង្កើតដោយខ្លួនឯង ឬប្រើប្រាស់ផ្ទាំងក្រដាសពត៌មានដែលរៀបចំដោយអង្គការ ILO ឬអង្គការដទៃទៀត

### តំលៃ:

$

$ តំលៃទាប
$$ តំលៃមធ្យម
$$$ តំលៃខ្ពស់